**សេចក្តីសង្ខេបអំពីបញ្ហា**

# អត្ថប្រយោជន៍នៃការត្រួតពិនិត្យថ្នាំជក់សម្រាប់ប្រជាជនកម្ពុជាដែលមានប្រាក់ចំណូលទាប

លទ្ធផលរកឃើញ និងភាពជាប់ពាក់ព័ន្ធផ្នែកគោលនយោបាយចេញពី *"ករណីវិនិយោគសម្រាប់ការត្រួតពិនិត្យថ្នាំជក់ក្នុងប្រទេសកម្ពុជា៖ ករណីសម្រាប់វិនិយោគទៅលើការអនុវត្តអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ (FCTC) របស់អង្គការសុខភាពពិភពលោក"*

តើអ្វីទៅជាករណីវិនិយោគ?

ករណីវិនិយោគសម្រាប់ការគ្រប់គ្រងថ្នាំជក់ក្នុងប្រទេសកម្ពុជាពិនិត្យទៅលើបន្ទុកនៃការប្រើប្រាស់ថ្នាំជក់ក្នុងប្រទេសកម្ពុជា។ ករណីនេះធ្វើការវិភាគវិសាលភាពថាតើការវិនិយោគទៅលើវិធានការសំខាន់ៗនៃ**អនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ (FCTC) របស់អង្គការសុខភាពពិភពលោក** ដែលអាចផ្តល់នូវផលចំណេញផ្នែកសុខភាព សេដ្ឋកិច្ច និងផ្នែកអភិវឌ្ឍន៍ផ្សេងទៀតបានកម្រិតណា ដោយធ្វើការពន្លឿនការសម្រេចបានរបស់ប្រទេសកម្ពុជា នូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDG)។

ហេតុអ្វីបានជាត្រូវអនុវត្តករណីវិនិយោគ?

ថ្នាំជក់សម្លាប់ជីវិតមនុស្ស បង្កឱ្យមានការខាតបង់ផ្នែកសេដ្ឋកិច្ច រួមចំណែកធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន និងគំរាម

## ការប្រើប្រាស់ថ្នាំជាក់ និងភាពក្រីក្រ

ការប្រើប្រាស់ថ្នាំជក់ និងភាពក្រីក្រមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ។ នៅគ្រប់តំបន់ទាំងអស់នៅលើពិភពលោក **ប្រជាជនដែលមានប្រាក់ចំណូលទាប និងមានកម្រិតវប្បធម៌ទាបមានទំនោរខ្ពស់ក្នុងការប្រើប្រាស់ថ្នាំជក់** ព្រមទាំងមិនសូវទទួលបានព័ត៌មានអំពីសុខភាព ក៏ដូចជាសេវាទប់ស្កាត់ និងព្យាបាលការប្រើប្រាស់ថ្នាំជក់។ ប្រទេសមានប្រាក់ចំណូលទាប និងប្រជាជននៅក្នុងសហគមន៍ជួបការលំបាក តែងតែជាគោលដៅរបស់ឧស្សាហកម្មថ្នាំជក់។

**រូបភាពទី 1៖ ប្រេវ៉ាឡង់ជក់បារីតាមកម្រិតប្រាក់ចំណូល**




នៅក្នុងប្រទេសកម្ពុជា ប្រជាជននៅក្នុងបញ្ចភាគប្រាក់ចំណូលទាបបំផុត (ពោលគឺ 20 ភាគរយទាបជាងគេ) កាន់តែមានទំនោរក្នុងការជក់បារី (26.1 ភាគរយ) ខ្ពស់ជាងប្រជាជននៅក្នុងបញ្ចភាគប្រាក់ចំណូលខ្ពស់ជាង (9.4 ភាគរយ)[1]

[1] តួលេខ និងរូបភាពដែលប្រើប្រាស់ក្នុងឯកសារសង្ខេបនេះ លុះត្រាតែមានកំណត់សម្គាល់ផ្សេងពីនេះ គឺយកមកពី ឬដកស្រង់ចេញពីក្នុងឯកសារស្តីពី *ករណីវិនិយោគសម្រាប់ការត្រួតពិនិត្យថ្នាំជក់ក្នុងប្រទេស*

។ (រូបភាពទី 1)

ស្រដៀងគ្នានេះដែរ បុរសដែលមិនបានចូលរួមឬបានចូលរៀនត្រឹមកម្រិតបឋម មានទំនោរខ្ពស់ក្នុងការជក់បារី(59 និង42ភាគរយ រៀងៗខ្លួន) ខ្ពស់ជាងបុរសដែលបានទទួលការអប់រំចាប់ពីកម្រិតមធ្យមសិក្សាឡើងទៅ(21 ភាគរយ)[2]។ (រូបភាពទី 2)។

**រូបភាពទី 2៖ ប្រេវ៉ាឡង់ជក់បារីតាមកម្រិតវប្បធម៌ (បុរស)**




ការប្រើប្រាស់ថ្នាំជក់បង្កឱ្យមានការលំបាកផ្នែកហិរញ្ញវត្ថុធ្ងន់ធ្ងរនៅក្នុងគ្រួសារ ប្រាក់ចំណូលទាបតាមរយៈការចំណាយប្រាក់ចេញពីហោប៉ៅសម្រាប់ជំងឺពាក់ព័ន្ធនឹងថ្នាំជក់ ដែលរួមមានដូចជាជំងឺមហារីក និងជំងឺបេះដូង ព្រមទាំងការស្លាប់មុនអាយុនៃជនបង្គោលក្នុងគ្រួសារទៀតផង។

ការចំណាយទៅលើថ្នាំជក់ ដែលជាផលិតផលធ្វើឱ្យញៀន ក៏ធ្វើឱ្យគ្រួសារបាត់បង់ធនធានមួយចំណែកធំពីការវិនិយោគទៅលើផលិតភាព ដូចជា អាហារ ការអប់រំ ការថែទាំសុខភាពលំនៅដ្ឋាន និងការប្រើប្រាស់ធាតុចូលកសិកម្មជាដើម ដែលអាចជួយរក្សា និងសង្គ្រោះប្រជាជនចេញពីភាពក្រីក្របាន។

គ្រួសារប្រាក់ចំណូលទាប បាត់បង់ប្រាក់ចំណូលដែលមានកម្រិតទាបស្រាប់ទៅលើផលិតផលថ្នាំជក់ ក្នុងចំនួនខ្ពស់ជាងគ្រួសារដែលមានប្រាក់ចំណូលខ្ពស់។ នៅក្នុងប្រទេសកម្ពុជា អ្នកជក់បារីរកប្រាក់ចំណូលបានចាប់ពី 2 ដុល្លារអាមេរិកចុះ

កំហែងយ៉ាងធ្ងន់ធ្ងរដល់ការអភិវឌ្ឍប្រកបដោយចីរភាព។ ប្រជាជនកម្ពុជាប្រមាណ 2.4 លាននាក់ ឬប្រមាណ 22 ភាគរយ ដែលមានអាយុចាប់ពី 15 ឆ្នាំឡើងទៅ ប្រើប្រាស់ថ្នាំជក់តាមរូបភាពផ្សេងៗ ហើយកាន់តែប្រឈមចំពោះជំងឺផ្សេងៗ ការស្លាប់មុនអាយុ និងការធ្លាក់ទៅក្នុងភាពក្រីក្រ។ ចាំបាច់ត្រូវមានការត្រួតពិនិត្យថ្នាំជក់កាន់តែរឹងមាំ និងកាន់តែមានប្រសិទ្ធភាព ដើម្បីឱ្យប្រទេសកម្ពុជាអាចកាត់បន្ថយការខាតបង់ផ្នែកសុខភាព សេដ្ឋកិច្ច និងការអភិវឌ្ឍន៍។ ចាំបាច់ត្រូវមានភស្តុតាងបែបវិទ្យាសាស្ត្រ ដើម្បីរៀបចំ និងគាំទ្រដល់ការបង្កើតគោលនយោបាយ។

### តើលទ្ធផលសំខាន់ៗមានអ្វីខ្លះ?

ការត្រួតពិនិត្យថ្នាំជក់ គឺដើម្បីគាំទ្រប្រជាជនក្រីក្រ ដែលជួយផ្តល់នូវផលប្រយោជន៍យ៉ាងច្រើនដល់ប្រជាជនក្រីក្រ។

ថ្នាំជក់ធ្វើឱ្យខាតបង់ទឹកប្រាក់ប្រមាណ 2.7 ទ្រីលានរៀល (663 លានដុល្លារអាមេរិក) ជារៀងរាល់ឆ្នាំ ដែលស្មើនឹង 3 ភាគរយនៃផលិតផលក្នុងស្រុកសរុបរបស់ប្រទេសកម្ពុជា។

នៅក្នុងឆ្នាំ2017 ការប្រើប្រាស់ថ្នាំជក់បានធ្វើឱ្យបាត់បង់អាយុជីវិតប្រជាជនប្រមាណ 15,000 នាក់នៅក្នុងប្រទេស

---

*កម្ពុជា៖ ករណីសម្រាប់វិនិយោគទៅលើការអនុវត្តអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ (FCTC) របស់អង្គការសុខភាពពិភពលោក* (ឆ្នាំ2019) របស់អង្គការ RTI កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) លេខាធិការដ្ឋាន FCTC របស់អង្គការសុខភាពពិភពលោក និងអង្គការសុខភាពពិភពលោក។

[2] ក្រសួងផែនការ ក្រសួងសុខាភិបាល និងអង្គការ ICF International *ការស្ទង់មតិអំពីប្រជាសាស្ត្រ និងសុខាភិបាលកម្ពុជា ឆ្នាំ2014* (រាជធានីភ្នំពេញ ឆ្នាំ2015)។

កម្ពុជា ដែលក្នុងចំនួននោះ មាន 33 ភាគរយបានកើតឡើងនៅក្នុងក្រុមមានប្រាក់ចំណូលទាបជាងគេក្នុងចំណោម 20 ភាគរយ។

ការវិនិយោគទៅលើវិធានការត្រួតពិនិត្យថ្នាំជក់ទាំងប្រាំ នឹងជួយសង្គ្រោះអាយុជីវិតប្រជាជនចំនួន 57,000 នាក់ និងការពារការខាតបង់ទឹកប្រាក់ចំនួន 7.9 ទ្រីលានរៀល (1.9 ប៊ីលានដុល្លារអាមេរិក) ទៅលើការចំណាយផ្នែកសុខភាព និងការខាតបង់ផ្នែកសេដ្ឋកិច្ចនៅត្រឹមឆ្នាំ2033។

សម្រាប់ទឹកប្រាក់ចំនួនមួយរៀលដែលបានវិនិយោគទៅលើវិធានការត្រួតពិនិត្យថ្នាំជក់ទាំងប្រាំនៅពេលនេះ ប្រទេសកម្ពុជានឹងទទួលបានមកវិញនូវទឹកប្រាក់ចំនួន 178 រៀល ដែលបានមកពីការទប់ស្កាត់ការចំណាយ និងការខាតបង់ផ្នែកសេដ្ឋកិច្ចនៅត្រឹមឆ្នាំ2033 ឬអាចនិយាយបានម៉្យាងទៀតថា វិធានការត្រួតពិនិត្យថ្នាំជក់មានប្រសិទ្ធភាពខ្ពស់ និងជាការវិនិយោគដ៏ឆ្លាតវៃសម្រាប់ប្រទេសកម្ពុជាផងដែរ។

ក្រោមក្នុងមួយថ្ងៃ តែចំណាយប្រាក់ប្រមាណ 6 ដុល្លារអាមេរិក (24,000 រៀល) ក្នុងមួយខែ ទៅលើថ្នាំជក់ ដែលស្មើនឹង **10 ភាគរយឡើងទៅនៃប្រាក់ចំណូលប្រចាំខែរបស់ខ្លួន**។[3]

ហេតុដូច្នេះ **ការកាត់បន្ថយ ឬការបញ្ចៀសចំណាយប្រចាំគ្រួសារទៅលើផលិតផលថ្នាំជក់ និងជំងឺផ្សេងៗកើតឡើងដោយសារថ្នាំជក់ អាចជួយរក្សាធនធានសំខាន់ៗសម្រាប់គ្រួសារប្រាក់ចំណូលទាប** ដែលមានសារៈសំខាន់ក្នុងការជួយសង្គ្រោះពួកគាត់ចេញពីភាពក្រីក្រ និងកាត់បន្ថយវិសមភាពនៅក្នុងប្រទេសកម្ពុជា។

---

3 ក្រសួងផែនការនៃប្រទេសកម្ពុជា ការស្ទង់មតិចំពោះមនុស្សពេញវ័យថ្នាក់ជាតិអំពីថ្នាំជក់នៅក្នុងប្រទេសកម្ពុជា (រាជធានីភ្នំពេញ ឆ្នាំ2015)។

## ប្រជាជនប្រាក់ចំណូលទាបទទួលបានអត្ថប្រយោជន៍ខ្ពស់បំផុតពីការដំឡើងពន្ធលើថ្នាំជក់

*ករណីវិនិយោគសម្រាប់ការត្រួតពិនិត្យថ្នាំជក់ក្នុងប្រទេសកម្ពុជា*[4] ធ្វើការប៉ាន់ស្មានថាតើ ការដំឡើងពន្ធលើបារី (ធ្វើឱ្យតម្លៃលក់រាយកើនឡើង 28 ភាគរយ ដោយអនុវត្តតាមផែនទីបង្ហាញផ្លូវស្តីពីពន្ធលើថ្នាំជក់ ឆ្នាំ2019-2023[5] របស់ប្រទេសកម្ពុជា) នឹងមានឥទ្ធិពលទៅលើប្រជាជននៅក្នុងបញ្ចភាគប្រាក់ចំណូលខុសៗគ្នា។ ដោយសារប្រជាជនប្រាក់ចំណូលទាបមានការឆ្លើយតបខ្ពស់ចំពោះការប្រែប្រួលតម្លៃថ្នាំជក់ **ទើបការដំឡើងពន្ធនឹងធ្វើឱ្យប្រេវ៉ាឡង់ជក់បារីមានការធ្លាក់ចុះខ្លាំងបំផុតនៅក្នុងបញ្ចភាគប្រាក់ចំណូលទាបជាងគេបំផុត** (2.8 ភាគរយ) បើធៀបជាមួយបញ្ចភាគប្រាក់ចំណូលផ្សេងទៀត (ធ្លាក់ចុះ 0.4 ភាគរយនៅក្នុងបញ្ចភាគប្រាក់ចំណូលខ្ពស់បំផុត) (រូបភាពទី 3)។

**រូបភាពទី 3៖ ការកាត់បន្ថយប្រេវ៉ាឡង់មុន/បន្ទាប់ពីដំឡើងពន្ធ**




**ការធ្លាក់ចុះខ្លាំងបំផុតនៃប្រេវ៉ាឡង់ជក់បារីមានន័យថា បញ្ចភាគប្រាក់ចំណូលទាបបំផុតនឹងទទួលបានអត្ថប្រយោជន៍សុខភាពក្នុងចំណែកធំបំផុត។** ជាក់ស្តែង ការស្លាប់ចំនួន 1,171 នាក់នឹងត្រូវបានទប់ស្កាត់តាមរយៈការដំឡើងពន្ធ ដែលចំនួនជិតពាក់កណ្តាល (46 ភាគរយ) ស្ថិតនៅក្នុងចំណោមបញ្ចភាគប្រាក់ចំណូលទាបបំផុត។

**ក្រុមប្រាក់ចំណូលទាបនឹងទទួលបានអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចមិនស្មើគ្នា** តាមរយៈការកាត់បន្ថយក្នុងអត្រាខ្ពស់ជាងនូវការចំណាយលើសលុបទៅលើបញ្ហាសុខភាព[6]។ ការដំឡើងពន្ធនឹងទប់ស្កាត់ការចំណាយលើសលុបទៅលើបញ្ហាសុខភាពបានចំនួន 17,000 ករណី ដែលក្នុងចំណោមនោះចំនួន 53 ភាគរយស្ថិតនៅក្នុងបញ្ចភាគប្រាក់ចំណូលទាបបំផុត និងទាបបំផុតទីពីរ។ (រូបភាពទី 4)។

---

4 *ករណីវិនិយោគសម្រាប់ការត្រួតពិនិត្យថ្នាំជក់ក្នុងប្រទេសកម្ពុជា៖ ករណីសម្រាប់វិនិយោគទៅលើការអនុវត្តអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ (FCTC) របស់អង្គការសុខភាពពិភពលោក* របស់អង្គការ RTI កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) លេខាធិការដ្ឋាន FCTC របស់អង្គការសុខភាពពិភពលោក និងអង្គការសុខភាពពិភពលោក។

5 សម្រាប់ព័ត៌មានបន្ថែម សូមមើលជំពូក 6 នៃ*ករណីវិនិយោគសម្រាប់ការត្រួតពិនិត្យថ្នាំជក់ក្នុងប្រទេសកម្ពុជា* (ឆ្នាំ2019)។

6 កំណត់និយមន័យថាជា "ការចំណាយចេញពីហោប៉ៅដែលមានចំនួនលើសពី 40 ភាគរយនៃការចំណាយក្រៅពីការចិញ្ចឹមជីវិតរបស់គ្រួសារមួយ។"

**ការទប់ស្កាត់ការចំណាយលើសលុបទៅលើបញ្ហាសុខភាពក៏អាចជួយទប់ស្កាត់មនុស្សចំនួនជិត 1,500 នាក់មិនឱ្យធ្លាក់ទៅក្នុងភាពក្រីក្រជារៀងរាល់ឆ្នាំនៅក្នុងប្រទេសកម្ពុជាបានផងដែរ។**

ជាងនេះទៅទៀត **បន្ទុកពន្ធគឺមានកម្រិតទាបជាងទៅលើប្រជាជនប្រាក់ចំណូលទាប ដោយសារពួកគាត់ឈប់ទិញ និងប្រើប្រាស់ថ្នាំជក់ក្នុងអត្រាខ្ពស់ជាងអ្នកមាននៅពេលតម្លៃថ្នាំជក់កើនឡើង។** ខណៈដែលបញ្ចភាគប្រាក់ចំណូលទាបបំផុត នឹងបង្កើនការចំណាយទៅលើបារីចំនួន 14 ភាគរយ ដោយសារការកើនឡើងនៃថ្លៃ ទន្ទឹមនឹងនេះតួលេខដូចគ្នាសម្រាប់បញ្ចភាគប្រាក់ចំណូលខ្ពស់បំផុតមានចំនួន 22 ភាគរយ។ កត្តានេះមានន័យថា ការដំឡើងបន្ទុកពន្ធនឹងបង្កើតបន្ទុកមិនស្មើគ្នាទៅលើអ្នកជក់បារីដែលជាអ្នកមានទ្រព្យសម្បត្តិខ្ពស់ជាង។ ជាងនេះទៅទៀត ការដំឡើងពន្ធដែលនាំឱ្យថ្លៃបារីកើនឡើង ជាការបង្អាក់អ្នកមិនជក់បារី ដែលក្នុងនោះក៏មានយុវជនផងដែរ មិនឱ្យចាប់ផ្តើមជក់បារី លើកទឹកចិត្តអ្នកជក់បារីបច្ចុប្បន្នឱ្យឈប់ជក់បារី និងបង្អាក់អ្នកធ្លាប់ជក់បារីមិនឱ្យចាប់ផ្តើមជក់បារីឡើងវិញ។

**រូបភាពទី 4៖ ករណីចំណាយលើសលុបលើបញ្ហាសុខភាពដែលត្រូវបានបញ្ចៀសបន្ទាប់ពីការដំឡើងពន្ធ គិតតាមបញ្ចភាគប្រាក់ចំណូល**




ករណីវិនិយោគក៏បានរកឃើញផងដែរថា **ការដំឡើងពន្ធបារីផ្តល់បានផលចំណេញខ្ពស់បំផុតទៅលើការវិនិយោគក្នុងចំណោមវិធានការត្រួតពិនិត្យថ្នាំជក់អាទិភាពនានា៖** សម្រាប់ទឹកប្រាក់មួយរៀលដែលបានវិនិយោគ ប្រទេសកម្ពុជាអាចទទួលបានមកវិញនូវទឹកប្រាក់ចំនួន 882 រៀលជាអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនៅក្នុងរយៈ 15 ឆ្នាំ។

ជាងនេះទៅទៀត ការដំឡើងអត្រាពន្ធ និងការអនុវត្តកំណែទម្រង់រចនាសម្ព័ន្ធពន្ធយោងតាមផែនទីបង្ហាញផ្លូវស្តីពីពន្ធលើថ្នាំជក់របស់ប្រទេសកម្ពុជា អាចរកទឹកប្រាក់បន្ថែមបានចំនួន 920 ប៊ីលានរៀល ដែលជាប្រាក់ចំណូលពន្ធរដ្ឋាភិបាល នៅក្នុងរយៈពេលប្រាំឆ្នាំដំបូងបន្ទាប់ពីការផ្លាស់ប្តូរនេះ។ ប្រាក់ចំណូលបន្ថែមអាចប្រើប្រាស់ដើម្បីផ្តល់ហិរញ្ញប្បទានដល់វិធានការគាំទ្រប្រជាជនក្រីក្រ ដូចជា សេវាគ្របដណ្តប់សុខភាពជាសកល និងការជួយកសិករដាំថ្នាំជក់ឱ្យផ្លាស់ប្តូរទៅដាំដំណាំផ្សេង ឬប្រកបមុខរបរផ្សេងទៀត។

**អត្រាពន្ធបារីរបស់ប្រទេសកម្ពុជាមានកម្រិតទាបជាងគេក្នុងចំណោមបណ្តាប្រទេសអាស៊ាន** ដែលទាបជាងឆ្ងាយពីកម្រិតដែលផ្តល់អនុសាសន៍ដោយ WHO FCTC និងមានឱកាសច្រើននៅក្នុងការដំឡើងពន្ធថែមទៀត។ ទន្ទឹមនឹងនេះ ប្រជាជនកម្ពុជាក៏កាន់តែមានលទ្ធភាពខ្ពស់ក្នុងការទិញបារីផងដែរ[7] ដោយសារសេដ្ឋកិច្ចជាតិ និងប្រាក់ចំណូលរបស់ប្រជាជនមានការកើនឡើង។

ការព្រួយបារម្ភដែលច្រើនកើតឡើងនោះគឺថា ពន្ធលើផលិតផលថ្នាំជក់អាចមានឥទ្ធិពលមិនស្មើគ្នាទៅលើអ្នកប្រើប្រាស់ថ្នាំជក់ប្រាក់ចំណូលទាប ដោយសារតែបន្ទុកពន្ធបង្ហាញអំពីចំណែកប្រាក់ចំណូលរបស់គាត់ក្នុងកម្រិតខ្ពស់ជាងចំណែកប្រាក់ចំណូលរបស់អ្នកប្រើប្រាស់ថ្នាំជក់ដែលមានទ្រព្យសម្បត្តិច្រើនជាង។ ទោះជាយ៉ាងនេះ មានភ័ស្តុតាងបង្ហាញថា **ប្រជាជនក្រីក្រពិតជាអាចទទួលបានប្រយោជន៍ខ្ពស់ជាងគេពីការដំឡើងពន្ធលើថ្នាំជក់។** បើប្រៀបធៀបជាមួយអ្នកប្រើប្រាស់ថ្នាំជក់ដែលមានប្រាក់ចំណូលខ្ពស់ជាង អ្នកប្រើប្រាស់ថ្នាំជក់ប្រាក់ចំណូលទាប កាន់តែមានទំនោរក្នុងការបោះបង់ការប្រើប្រាស់ថ្នាំជក់ នៅពេលពន្ធលើថ្នាំជក់ត្រូវបានដំឡើង ដែលមានន័យថា ពួកគាត់មានការថយចុះនូវបញ្ហាសុខភាពពាក់ព័ន្ធនឹងថ្នាំជក់ និងការចំណាយផ្នែកសុខភាព និងសេដ្ឋកិច្ចដែលបណ្តាលមកពីថ្នាំជក់។

ធនាគារពិភពលោកអះអាងថា "ភ័ស្តុតាងដែលប្រមូលបានពីទូទាំងពិភពលោកបង្ហាញអំពីរបៀបដែលពន្ធលើថ្នាំជក់អាចកាត់បន្ថយភាពក្រីក្រ... [T] ពន្ធលើថ្នាំជក់ពុំមែនជាពន្ធអវឌ្ឍនៈនោះទេ តែជាពន្ធដែលកំណត់ទៅតាមកម្រិតប្រាក់ចំណូល ដោយសារអត្ថប្រយោជន៍ពេញលេញចំពោះសុខភាព និងសេដ្ឋកិច្ចមានកម្រិតលុបលើចំណាយដែលពាក់ព័ន្ធ"[8]។

សរុបរួមមក **គោលនយោបាយត្រួតពិនិត្យថ្នាំជក់ ជាពិសេសការដំឡើងពន្ធលើថ្នាំជក់ អាចផ្តល់ប្រយោជន៍ទៅដល់ប្រជាជនប្រាក់ចំណូលទាបចំនួនពីរជង៖** ទីមួយ ការពារសុខភាព កាត់បន្ថយការចំណាយទៅលើផ្នែកសុខភាព ដោយធ្វើឱ្យគ្រួសារមាននូវធនធានសម្រាប់ការវិនិយោគទៅលើ

---

[7] ដកស្រង់ចេញពី *កំណែទម្រង់បង្កើនពន្ធលើថ្នាំជក់កម្រិតអតិបរិមានៅក្នុងប្រទេសមីយ៉ាន់ម៉ា* (ទីក្រុងបាងកក ឆ្នាំ2017) របស់សម្ព័ន្ធត្រួតពិនិត្យថ្នាំជក់អាស៊ីអាគ្នេយ៍ (SEATCA)។

[8] ធនាគារពិភពលោក *កំណែទម្រង់ពន្ធលើថ្នាំជក់៖ នៅផ្លូវបំបែកនៃសុខាភិបាល និងការអភិវឌ្ឍន៍* (វ៉ាស៊ីនតោន ឌីស៊ី ឆ្នាំ2017)។

ផលិតភាពផ្សេងៗ និងទប់ស្កាត់ការធ្លាក់ចូលទៅក្នុងភាពក្រីក្រ ដែលនឹងបង្កើនចំនួនឆ្នាំធ្វើការ ព្រមទាំងសក្តានុពលរកប្រាក់ចំណូលផ្សេងៗទៀតរបស់ប្រជាជន និងទីពីរ តាមរយៈការវិនិយោគទៅវិញនូវប្រាក់ចំណូលបន្ថែមរបស់រដ្ឋាភិបាលដែលទទួលបានពីការយកពន្ធលើថ្នាំជក់ រួមជាមួយនឹងការសន្សំសំចៃរយៈពេលវែងពីការចំណាយទៅលើការថែទាំសុខភាព ទៅលើវិធានការអភិវឌ្ឍន៍ដែលជួយដល់ប្រជាជនក្រីក្រ។

លទ្ធផលរកឃើញពីករណីវិនិយោគជួយបន្ថែមទៅលើភស្តុតាងជាសាកលដែលមានស្រាប់ អំពីឥទ្ធិពលដែលជួយដល់ជនក្រីក្រ ជួយលើបញ្ហាសុខភាព និងជួយទៅលើផ្នែកសេដ្ឋកិច្ចនៃការត្រួតពិនិត្យថ្នាំជក់ ជាពិសេសការដំឡើងពន្ធលើបារី។ យើងអាចនិយាយបានម៉្យាងទៀតថា **ការត្រួតពិនិត្យថ្នាំជក់ គឺជាការវិនិយោគគោលនយោបាយជួយប្រជាជនក្រីក្រដែលជួយទប់ស្កាត់ និងកាត់បន្ថយភាពក្រីក្រ លើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន កាត់បន្ថយវិសមភាពសង្គម និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច** ដែលពន្លឿនដំណើរការអភិវឌ្ឍន៍របស់ប្រទេសឆ្ពោះទៅសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDG)[9]។

ចាប់តាំងពីបានដាក់ឱ្យអនុវត្តកាលពីឆ្នាំ2019 ជាផ្នែកមួយនៃគម្រោង FCTC 2030 ករណីវិនិយោគមាននូវផែនការសកម្មភាពយុទ្ធសាស្ត្រជាតិត្រួតពិនិត្យថ្នាំជក់របស់ប្រទេសកម្ពុជា ឆ្នាំ2020-24 ដែលរួមមាន ការពង្រឹងគោលនយោបាយសារពើពន្ធលើថ្នាំជក់។ លទ្ធផលសម្រេចបាននាពេលថ្មីៗផ្សេងទៀតនូវគម្រោង FCTC 2030 រួមមានដូចខាងក្រោម៖

- សណ្ឋាគារចំនួន 37 និងភោជនីយដ្ឋានចំនួន 26 ដែលបានវាយតម្លៃនៅក្នុងខេត្តកំពង់ចាម សៀមរាប និងបាត់ដំបង បានទទួលពានរង្វាន់ស្នាដៃឆ្នើមក្នុងការអនុវត្តគោលការណ៍បរិស្ថានគ្មានផ្សែងបារី ក្នុងវិស័យទេសចរណ៍ឆ្នាំ2019-2020 ពីក្រសួងទេសចរណ៍។
- នៅក្នុងឆ្នាំ2020 ការវាយតម្លៃ និងការផ្តល់ពានរង្វាន់នឹងត្រូវអនុវត្តនៅក្នុងខេត្តចំនួនប្រាំមួយបន្ថែមទៀត ហើយត្រូវបានរំពឹងថា នឹងទទួលបានសណ្ឋាគារ/ផ្ទះសំណាក់ និងភោជនីយដ្ឋានចំនួន 120 នៅក្នុងចំណោមសណ្ឋាគារ/ផ្ទះសំណាក់ និងភោជនីយដ្ឋានចំនួន 240 ដែលទទួលបានពានរង្វាន់បរិស្ថានគ្មានផ្សែងបារីក្នុងវិស័យទេសចរណ៍ឆ្នាំ2020។

[9] កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) លេខាធិការដ្ឋាន FCTC របស់អង្គការសុខភាពពិភពលោក និងអង្គការសុខភាពពិភពលោក សេចក្តីសង្ខេបគោលនយោបាយ៖ ការត្រួតពិនិត្យថ្នាំជក់ជាកត្តាពន្លឿនសម្រាប់គោលដៅអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងប្រទេសកម្ពុជា (ឆ្នាំ2018) ។

ជាចុងក្រោយ ដោយសារការវិភាគរបស់អង្គការសុខភាពពិភពលោករកឃើញថា ការជក់បារីមានជាប់ពាក់ព័ន្ធនឹងកំណើនភាពធ្ងន់ធ្ងរនៃករណីជំងឺ និងករណីស្លាប់ទៅលើអ្នកជំងឺកូវីដ 19 ដែលសម្រាកព្យាបាលនៅមន្ទីរពេទ្យ[10] និងតួនាទីដ៏សំខាន់នៃសេវាគ្របដណ្តប់សុខភាពសកល និងកិច្ចគាំពារសង្គម ដែលអាចគាំទ្របានតាមរយៈការយកពន្ធលើថ្នាំជក់ **ការត្រួតពិនិត្យថ្នាំជក់ក៏រួមចំណែកដល់ការកាត់បន្ថយភាពងាយរងគ្រោះ និងលើកកម្ពស់ភាពធន់របស់ប្រទេសកម្ពុជានៅក្នុងស្ថានភាពអាសន្នផ្នែកសុខភាពផងដែរ។**

**អនុសាសន៍៖**

- ដំឡើងពន្ធលើថ្នាំជក់ជាបន្តបន្ទាប់យ៉ាងតិចឱ្យបាន 75 ភាគរយនៃតម្លៃលក់រាយ(បច្ចុប្បន្ន 25-31 ភាគរយ) ដោយត្រូវដំឡើងតាមពេលវេលាកំណត់ ដើម្បីលុបលើអតិផរណា និងកំណើនប្រាក់ចំណូល។
- ពិចារណាទៅលើការបែងចែកប្រាក់ចំណូលពន្ធលើថ្នាំជក់មួយចំណែកសម្រាប់ការត្រួតពិនិត្យថ្នាំជក់ និងវិធានការជួយប្រជាជនក្រីក្រ ដូចជា សេវាគ្របដណ្តប់សុខភាពសកល ការជួយដល់កសិករ និងបុគ្គលិកថ្នាំជក់ឱ្យប្តូរទៅរកមុខរបរចិញ្ចឹមជីវិតផ្សេង ឬគម្រោងគាំពារសង្គមផ្សេងៗទៀត។
- លើកកម្ពស់ការយល់ដឹងក្នុងចំណោមសាធារណៈជន និងអ្នករៀបចំគោលនយោបាយអំពីចំណាយពិតប្រាកដទៅលើថ្នាំជក់ និងអត្ថប្រយោជន៍ដ៏ច្រើនចំពោះសុខភាព និងការអភិវឌ្ឍប្រទេសជាតិ ជាពិសេសក្នុងចំណោមប្រជាជនប្រាក់ចំណូលទាប។
- ធានាថា គ្រប់វិស័យពាក់ព័ន្ធទាំងអស់បានចូលរួមនៅក្នុងកិច្ចខិតខំប្រឹងប្រែងត្រួតពិនិត្យថ្នាំជក់ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ មានប្រសិទ្ធភាព និងប្រកបដោយចីរភាព ខណៈដែលការពារដល់ការរៀបចំគោលនយោបាយមិនឱ្យមានការអន្តរាគមន៍ពីជ្រៀតជ្រែកពីឧស្សាហកម្មថ្នាំជក់។

**សេចក្តីថ្លែងអំណរគុណ៖** ក្រុមការងាររៀបចំឯកសារសម្រាប់សេចក្តីសង្ខេបបញ្ហានេះរួមមាន Richard Marshall, Runsinarith Phim, Amara Bou, Dudley Tarlton, Kazuyuki Uji និង Mashida Rashid មកពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ Nargiza Khodjaeva និង Daravuth Yel មកពីអង្គការសុខភាពពិភពលោក និង Ferdinand Strobel និង Trinette Lee មកពីលេខាធិការដ្ឋានអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ (FCTC) នៃអង្គការសុខភាពពិភពលោក។

[10] អង្គការសុខភាពពិភពលោក សេចក្តីសង្ខេបវិទ្យាសាស្ត្រ៖ ការជក់បារី និងជំងឺកូវីដ 19 ថ្ងៃទី26 ខែឧសភា ឆ្នាំ2020។ អាចរកបាននៅ https://www.who.int/publications/i/item/smoking-and-covid-19